អង្គការសហគមន៍ធាងត្នោត

Sahmakum Teang Tnaut Organization • a Cambodian Urban NGO

# របាយការណ៍សកម្មភាពប្រចាំឆ្នាំ
# ២០២៥


**អង្គការសមាគមធាងត្នោត (STT)**

**អាសយដ្ឋាន:** ផ្ទះលេខ២១ ផ្លូវ៤៧២ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

Email: info@teangtnaut.org ប្រអប់សំបុត្រលេខ: ១៧៤ ភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទលេខ: (+៨៥៥) ០២៣ ៤៣១ ៥៥៥

# ១.សេចក្តីផ្តើម

**អង្គការសមាគមធាងត្នោត**ត្រូវបានបង្កើតឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០០៥ និងត្រូវបានចុះបញ្ជី ជាផ្លូវការ នៅក្រសួងមហាផ្ទៃ ក្នុងខែធ្នូ ឆ្នាំ២០០៦។ អង្គការសមាគមធាងត្នោតគឺជាអង្គការមិនមែនរដ្ឋាភិបាលធ្វើការលើការអភិវឌ្ឍទីក្រុង ដែលគាំទ្រដល់សហគមន៍ក្រីក្រតាមរយៈការផ្តល់នូវជំនួយបច្ចេកទេសដល់សហគមន៍ទាំងនោះ ដោយផ្តោតសំខាន់លើការផលិតផែនទីសហគមន៍ និងការផ្តល់ព័ត៌មានជាក់លាក់ដែលអាចទុកចិត្តបានចេញមកពីការសិក្សាស្រាវជ្រាវ ផ្តល់ឱ្យសហគមន៍ដែលងាយរងគ្រោះ ដើម្បីឱ្យពួកគាត់អាចប្រើជាឧបករណ៍ស្វែងរកការគាំទ្រមតិ ដើម្បីទទួលបានសិទ្ធិមានលំនៅឋានសមរម្យ។

## តំបន់គោលដៅរបស់អង្គការសមាគមធាងត្នោត



## ២. កម្មវិធីរបស់អង្គការសមាគមធាងត្នោត

ដើម្បីសម្រេចបាននូវទស្សនៈវិស័យ និងបេសកកម្មរបស់ខ្លួន អង្គការសមាគមធាងត្នោតបាននិងកំពុងធ្វើការលើគម្រោងចំនួន៥គឺៈ ១.គម្រោងផែនទី និងគំនិតផ្តួចផ្តើមទីក្រុង ២. គម្រោងពង្រឹងអំណាចសហគមន៍ និងបណ្តាញ ៣. គម្រោងអាយស៊ីធី និងប្រព័ន្ធផ្សព្វផ្សាយដើម្បីសហគមន៍ ៤. គម្រោងសិទ្ធិដីធ្លី និងលំនៅឋាន និង ៥.គម្រោងស្រាវជ្រាវ។

នៅក្នុងឆ្នាំ២០២៥ នេះអង្គការសមាគមធាងធ្នោតបានធ្វើការជាមួយក្រុមគោលដៅចំនួន ៣៨ សហគមន៍នៃខេត្តក្រុងចំនួន៧ ដែលគិតជាចំនួន**គ្រួសារ៥៤១២** ស្ត្រី**១២៣៥២នាក់** និងបុរស**១០១៩៤នាក់**។




## ២.១. ការពង្រឹងសមត្ថភាព

អង្គការសមាគមធាងត្នោត បានយកការពង្រឹងសមត្ថភាពក្រុមគោលដៅជាកត្តាចាំបាច់ និងជាមធ្យោបាយដ៏សំខាន់ក្នុងការធ្វើឱ្យក្រុមគោលដៅមានភាពជាម្ចាស់ ឯករាជ្យភាពក្នុងការសម្រេចចិត្ត តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពសហគមន៍គោលដៅ។ ការពង្រឹងសមត្ថភាពនេះ ត្រូវបានធ្វើឡើងជា៣ទម្រង់គឺ (១)វគ្គបណ្តុះបណ្តាល (២)ការផ្លាស់ប្តូរបទពិសោធន៍ និង(៣)ការប្រជុំប្រចាំត្រីមាស ដែលក្តោបលើប្រធានគន្លឹះមួយចំនួនដូចជា សិទ្ធិមានលំនៅឋានសមរម្យ ច្បាប់ភូមិបាល ច្បាប់អស្សាមិករណ៍ ភាពជាអ្នកដឹកនាំក្នុងសហគមន៍ ការដោះស្រាយទំនាស់ ការតស៊ូមតិ និងសុវត្ថិភាពលើប្រព័ន្ធឌីជីថល ជាដើម ។



វគ្គបណ្តុះបណ្តាលចំនួន៣១
បានធ្វើក្នុងឆ្នាំ២០២៥




ក្នុងឆ្នាំ២០២៥នេះ អង្គការសមាគមធាងត្នោតបានផ្តល់ (១)វគ្គបណ្តុះបណ្តាលចំនួន **៣១ដង** ដែលមានអ្នកចូលរួមចំនួន**៨០២នាក់** ស្ត្រី**៥៤០នាក់** និង បុរស**២៥១នាក់** មកពីសហគមន៍គោលដៅចំនួន៣៨ ដែលជាក្រុមគោលដៅក្នុងឆ្នាំ២០២៥។

ក្នុងឆ្នាំ២០២៥ នេះផងដែរ អង្គារសមាគមផាងត្នោត ក៏បានរៀបចំ (២)ទស្សនកិច្ចសិក្សាចំនួន **៩ដង** ដល់សហគមន៍គោលដៅដែលមានអ្នកចូលរួមចំនួន**៣០៣នាក់** ស្រ្តី**១១៦នាក់** បុរស**១៨៧នាក់**។ លើសពីនេះ(៣)កិច្ចប្រជុំប្រចាំត្រីមាសចំនួន **៦ដង** ក៏ត្រូវបានរៀបចំទាំងនៅទីក្រុងភ្នំពេញនិងខេត្ត ដែលមានអ្នកចូលរួមសរុបចំនួន**២១៣នាក់** ស្រ្តី**១៤៣នាក់** បុរស**៧០នាក់**។



ទស្សនកិច្ចសិក្សា ៩ដង អ្នកចូលរួម៣០៣នាក់ ស្រ្តី១១៦នាក់



ប្រជុំប្រចាំត្រីមាស ចំនួន៦ អ្នកចូលរួម២១៣នាក់ ស្រ្តី១៤៣នាក់

## ២.២. ជំនួយកែលម្អខ្នាតតូច

អង្គការសមាគមផាងត្នោត តែងតែផ្តល់ជំនួយកែលម្អខ្នាតតូចទៅកាន់ក្រុមគោលដៅតាមភាពចាំបាច់និងតម្រូវការជាក់ស្តែង តាមលទ្ធភាពរបស់ខ្លួន។នៅក្នុងឆ្នាំ២០២៥នេះ អង្គការសមាគមផាងត្នោតបានផ្តល់ជំនួយកែលម្អលំនៅឋាន ចំនួន **២៧ ខ្នងផ្ទះ** និងផ្តល់ភ្លើងបំភ្លឺផ្លូវចំនួន**១០ ដើម**។ ដោយសហគមន៍ទំនប់តាថ្លាងទទួលបានចំនួន **១៨ ខ្នងផ្ទះ** សហគមន៍អណ្តូងតាអៀង ចំនួន **៩ ខ្នងផ្ទះ** និងសហគមន៍បឹងត្របែកភូមិ៤ និងភូមិ៥ ទទួលបានភ្លើងបំភ្លឺផ្លូវចំនួន**១០ដើម**។ ការផ្តល់ជូននេះធ្វើឡើងស្របតាមតម្រូវការ និងភាពចាំបាច់របស់សហគមន៍ ដើម្បីចូលរួមធ្វើឱ្យប្រសើរឡើងនូវការរស់នៅរបស់សហគមន៍ ស្របតាមបម្រែបម្រួលអាកាសធាតុ។

ជំនួយកែលម្អខ្នាតតូចឆ្នាំ២០២៥



ភ្លើងបំភ្លឺផ្លូវ ១០ដើម



២៧ ខ្នងផ្ទះ



រូបតំណាង ផ្ទះដែលបានកែលម្អជូនសហគមន៍



រូបភាពភ្លើងបំភ្លឺផ្លូវដែលបានដំឡើងរួចរាល់

## ២.៣. ការតស៊ូមតិ និងយុទ្ធនាការ

អង្គការសមាគមធាងត្នោតក៏បានចូលរួមសហការរៀបចំវេទិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាមួយអង្គការដៃគូ សហគមន៍ និងអជ្ញាធរមូលដ្ឋាន។ ក្នុងឆ្នាំ២០២៥ នេះអង្គការសមាគមធាងត្នោតបានរៀបចំ និងសហការរៀបចំវេទិកាថ្នាក់ជាតិចំនួន **៦ដង** ដែលមានអ្នកចូលរួមសរុប **៧៦៥នាក់** ស្ត្រី**៣៥៨ នាក់** និងបុរស**៤០៧នាក់** ដែលក្តោបទៅលើប្រធានបទដែលពាក់ព័ន្ធដូចជា ទិវាសិទ្ធិមនុស្ស ទិវាសិទ្ធិលំនៅឋាន ទិវាបរិស្ថានជាដើម។

វេទិកាថ្នាក់ជាតិ

ដែលបានរៀបចំក្នុងឆ្នាំ២០២៥



៦ដង ៣៥៨នាក់ ៤០៧នាក់

ជាងនេះទៅទៀតអង្គការសមាគមធាងត្នោត ក៏បានចូលរួមជាមួយអង្គការដៃគូរ និងសហគមន៍មូលដ្ឋានរៀបចំនូវវេទិកាសាធាណៈ យុទ្ធនាការ និងទិវាផ្សេងៗ ចំនួន**១៦ដង** ដែលមានអ្នកចូលរួមសរុប **៣៦០២នាក់** ស្ត្រី**២២៥០នាក់** និងបុរស**១៣៥២នាក់** ដែលពាក់ព័ន្ធនិងប្រធានបទ សិទ្ធិមនុស្ស បម្រែបម្រួលអាកាសធាតុ បញ្ហាដីធ្លី។

យុទ្ធនាការ

ដែលបានរៀបចំក្នុងឆ្នាំ២០២៥



១៦ដង ៣៦០២ នាក់ ២២៥០នាក់




រូបភាពតំណាង យុទ្ធនាការថ្នាក់ក្រោមជាតិរបស់សហគមន៍




រូបភាពតំណាង វេទិការថ្នាក់ជាតិ

## ២.៤. ការស្រាវជ្រាវ និងបោះពុម្ពផ្សាយ

អង្គការសមាគមធាងត្នោត តែងតែផលិតរបាយការណ៍ស្រាវជ្រាវរាងរាល់ឆ្នាំ ដែលទាក់ទងនឹងប្រធានបទការអភិវឌ្ឍទីក្រុង អភិបាលកិច្ច បញ្ហាសិទ្ធិដីធ្លី។ ក្នុងឆ្នាំ២០២៥ បានបោះពុម្ពផ្សាយរបាយការណ៍ចំនួន **២** និង អត្ថបទស្រាវជ្រាវខ្លីៗចំនួន **៣**។ លើសពីនេះទៅទៀតអង្គការសមាគមធាងត្នោត ក៏បានផលិតផែនទីចំនួន **២** ជូនសហគមន៍សម្រាប់ប្រើប្រាស់ផងដែរ។



ផែនទីចំនួន ២ បានផលិត




របាយការណ៍ចំនួន ២ បានបោះពុម្ពផ្សាយ

## ២.៥ ប្រព័ន្ធផ្សព្វផ្សាយ

អង្គការសមាគមធាងត្នោត បានផលិតវីដេអូដែលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស សិទ្ធិដីធ្លី ដែលពាក់ព័ន្ធនឹងក្រុមគោលដៅរបស់ខ្លួន។ ក្នុងឆ្នាំ២០២៥នេះ អង្គការសមាគមធាងត្នោត បានផលិតវីដេអូចំនួន **២៨** ផ្សេងៗគ្នា ដែលទាក់ទងទៅនឹងប្រធានសិទ្ធិដីធ្លី និងសិទ្ធិមនុស្សដែលកើតមាននៅតំបន់គោលដៅ។




រូបតំណាងវីដូអេដែលបានផលិតក្នុងឆ្នាំ២០២៥




រូបតំណាងវីដូអេដែលបានផលិត២០២៥

## ២.៦ ការចូលរួមរបស់យុវជន

ដោយមើលឃើញពីសារៈសំខាន់នៃការចូលរួមរបស់យុវជន ក្នុងការដោះស្រាយបញ្ហា និងជាអ្នកបន្តវេន អង្គការសមាគមឆាងត្នោត បានបង្កើតសកម្មភាពមួយចំនួន ដើម្បីផ្សារភ្ជាប់យុវជនជាមួយនឹងសហគមន៍នៅក្នុងទីក្រុង ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងរបស់យុវជនទាក់ទង ផ្តល់ឱកាសឱ្យយុវជនចូលរួមចំណែក និងផ្តល់មតិយោបល់ក្នុងកិច្ចការអភិវឌ្ឍន៍ និងការរៀបចំទីក្រុង។ ការណ៍នេះ បានអនុញ្ញាតឱ្យយុវជនអនុវត្តន៍សិទ្ធិរបស់ពួកគេ និងលើកឡើងនូវការព្រួយបារម្ភ និងកង្វល់នានាអំពីការរចនាទីក្រុង ការដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងកាកសំណល់ ហេដ្ឋារចនាសម្ព័ន្ធចរាចរណ៍ និងបញ្ហាបរិស្ថានជាដើម តាមរយៈយុទ្ធនាការ ការលើកកម្ពស់យល់ដឹងជាសាធារណៈ ការអភិវឌ្ឍសមត្ថភាព និងសកម្មភាពនានាទាំងលើវេទិកាឌីជីថល និងតាមសិក្ខាសាលានានាជាដើម។

ក្នុងឆ្នាំ២០២៥ នេះអង្គការសមាគមឆាងត្នោតបានសម្របសម្រួល និងផ្តល់ (១)វគ្គបណ្តុះបណ្តាលចំនួន ២ (២) ការបោះជំរំយុវជនចំនួន១ (៣)ការប្រជុំចំនួន ៦ (៤)យុទ្ធនាការតស៊ូមតិរបស់យុវជនចំនួន ៦ (៥)ទស្សនកិច្ចសិក្សាចំនួន ២ (៦)ការជជែកដេញដោលចំនួន ១ និង (៧)សន្និបាតយុវជនប្រចាំឆ្នាំចំនួន ១។

| សកម្មភាព | ចំនួន | អ្នកចូលរួមសរុប | ស្ត្រី | បុរស |
|---|---|---|---|---|
| (១)វគ្គបណ្តុះបណ្តាល | ២ | ៣១ នាក់ | ១៩ នាក់ | ១២ នាក់ |
| (២)បោះជំរំយុវជន | ១ | ៤១ នាក់ | ១៨ នាក់ | ២៣ នាក់ |
| (៣)ការប្រជុំ | ៦ | ១០៦ នាក់ | ៦២ នាក់ | ៤១ នាក់ |
| (៤)យុទ្ធនាការតស៊ូមតិ | ៦ | ១៧៥ នាក់ | ១០៩ នាក់ | ៦៦ នាក់ |
| (៥)ទស្សនកិច្ចសិក្សា | ២ | ៤៩ នាក់ | ២៥ នាក់ | ២៤ នាក់ |
| (៦)ការជជែកដេញដោល | ១ | ១២០ នាក់ | ៤៥ នាក់ | ៧៥ នាក់ |
| (៧)សន្និបាតយុវជនប្រចាំឆ្នាំ | ១ | ៥១ នាក់ | ២៧ នាក់ | ២៤ នាក់ |

**កម្រងរូបភាពសកម្មភាពជាមួយយុវជន**







